**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្ដារអំពីការដាក់ឯកសារ**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 10-Jun-2013, 15:49
CMS/CFO: Uch Arun

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជសដ

ភាគីដាក់ឯកសារ: លោក ខៀវ សំផន

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: **បារាំង**

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០១៣

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយសាលាដំបូង សាធារណៈ/Public

ប្រភេទនៃចំណាត់

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

# ចម្លើយទៅនឹងការស្នើសុំដាក់ភស្តុតាងបន្ថែមលើកទី១នៃសហមេធាវីនាំមុខនៃដើមបណ្ដឹងរដ្ឋប្បវេណី ដោយអនុលោមតាមវិធាន៨៧.៤ នៃវិធានផ្ទៃក្នុង

---

ដាក់ដោយ៖

**សហមេធាវីការពារក្ដីលោក ខៀវ សំផន**

លោក គង់ សំអុន

លោកស្រី Anta GUISSÉ

លោក Artur VERCKEN

លោក Jacques VERGÈS

**អ្នកជំនួយការ**

លោកស្រី សេង សុជាតា

កញ្ញា Marie CAPOTORTO

កញ្ញា Mathilde CHIFFERT

ផ្ញើជូន៖

**អង្គជំនុំជម្រះតុលាការ**សាលាដំបូង

ចៅក្រម និល ណុន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យ៉ូ ឧត្ដារ៉ា

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ា សុខន

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Andrew CAYLEY

កញ្ញា Soumeya MEDJEBEUR

កញ្ញា Vera MANUELLO **មេធាវីនៃដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់**

កញ្ញា អ៊ុំច ស្រីផាត

អ្នកស្រី សុគន្ធ មោនីកា **ក្រុមមេធាវីខាងការពារក្ដីទាំងអស់**

កញ្ញា Blandine ZELLER

## សូមគោរពអង្គជំនុំជម្រះសាលាដំបូង

១. នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ ដើមបណ្តឹងរដ្ឋប្បវេណី ដោយអនុលោមតាមវិធាន ៨៧.៤ នៃវិធានផ្ទៃក្នុង បានដាក់ការស្នើសុំអង្គជំនុំជម្រះឱ្យអនុញ្ញាតបញ្ចូលទៅក្នុងការពិភាក្សាដេញដោល នូវខ្សែអាត់ថតបទសម្ភាស លោក ខៀវ សំផន តាមរលកវិទ្យុ បារាំង France Culture ដែលធ្វើឡើងកាលពីថ្ងៃទី២០ ខែសីហា ឆ្នាំ ២០០៧។ [1]

២. ឯកសារដែលបានបញ្ជូនទៅអង្គជំនុំជម្រះនេះ គឺជាខ្សែអាត់សម្លេងបទសម្ភាស លោក ខៀវ សំផន ដែលបានចាក់ផ្សាយដោយវិទ្យុ France Culture។ បទសម្ភាសនេះមានលក្ខណៈជាសាធារណៈ និងអាចរកបាននៅលើវែបសាយនៃវិទ្យុ France Culture។

៣. តាមរយៈការស្នើសុំនេះ សហមេធាវីការពារក្តី លោក ខៀវ សំផន សូមជំទាស់ទៅនឹងការស្នើសុំនោះ។ សហមេធាវីការពារក្តីវាយតម្លៃថា ការស្នើសុំរបស់សហមេធាវីនៃដើមបណ្តឹងរដ្ឋប្បវេណីមានលក្ខណៈយឺតយ៉ាវ និងមិនមានសម្អាងគ្រប់គ្រាន់ មិនអនុលោមតាមសេចក្តីបង្គាប់ដែលមានចែងក្នុងវិធានផ្ទៃក្នុង និងផ្ទុយពីសញ្ញាណនៃ "ការមានប្រយោជន៍នាំមកនូវយុត្តិធម៌" ដូចមានចែងក្នុងយុត្តិសាស្ត្រនៃតុលាការពិសេស និងយុត្តិសាស្ត្រនៃអង្គជំនុំជម្រះសាលាដំបូងរបស់ អ.វ.ត.ក។

## I. លទ្ធភាពក្នុងការទទួលបានភស្តុតាងដែលត្រូវការមុនពេលបើកការពិភាក្សាដេញដោលទៅលើអង្គសេចក្តី

៤. ដូចអង្គជំនុំជម្រះសាលាដំបូងធ្លាប់បានរំឭកជាច្រើនលើក[2]មកហើយ នៅពេលដែលមានការស្នើសុំដាក់បញ្ចូលឯកសារថ្មី បន្ទាប់ពីពេលបើកសវនាការ វិធាន៨៤.៤ នៃវិធានផ្ទៃក្នុងបានចែងថា ដំបូង ភាគីដែលស្នើសុំត្រូវ “ធ្វើឱ្យអង្គជំនុំជម្រះជឿជាក់ថា [...] ភស្តុតាងដែលបានស្នើសុំនោះពុំអាចរកបាននៅមុនពេលការចាប់ផ្តើមជំនុំជម្រះឡើយ”។

---

[1] ការស្នើសុំដាក់ភស្តុតាងបន្ថែមជូនអង្គជំនុំជម្រះសាលាដំបូង ដោយអនុលោមតាមវិធាន៨៧.៤ នៃវិធានផ្ទៃក្នុង ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ ឯកសារ **E289**។

[2] សេចក្តីសម្រេចទាក់ទិននឹងឯកសារថ្មីៗ និងបញ្ហាពាក់ព័ន្ធដទៃទៀត ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១២ ឯកសារ **E190** កថាខណ្ឌទី២១ ។ សូមអានផងដែរនូវចម្លើយរបស់អង្គជំនុំជម្រះទៅនឹងសំណើតាមវិធាន ៨៧.៤ នៃវិធានផ្ទៃក្នុងរបស់សហព្រះរាជអាជ្ញា ជនជាប់ចោទ នួន ជា និង ខៀវ សំផន (ឯកសារ E236/4/1, E265, E271, E276 et E276/1) ថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៣ ឯកសារ **E276/2** កថាខណ្ឌទី៣។
ចម្លើយទៅនឹងការស្នើសុំដាក់ភស្តុតាងបន្ថែមលើកទី១នៃសហមេធាវីនាំមុខនៃដើមបណ្តឹងរដ្ឋប្បវេណី ដោយអនុលោមតាមវិធាន៨៧.៤ នៃវិធានផ្ទៃក្នុង

៥. នៅក្នុងសេចក្តីសម្រេច E190 អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក បានគូសបញ្ជាក់ថាការយោងទៅលើយុត្តិសាស្ត្រអន្តរជាតិសមស្រប បង្ហាញថាសញ្ញាណនៃ "ការរកបាន" នូវឯកសារភស្តុតាង អាចជាប់ទាក់ទងទៅនឹងសញ្ញាណនៃការប្រឹងប្រែងអស់លទ្ធភាព។[3]

៦. ដើម្បីជាសម្អាង អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក ក៏បានយោងទៅលើយុត្តិសាស្ត្រអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី។ យុត្តិសាស្ត្រនេះបានសន្និដ្ឋានថា នៅពេលដែលភាគីណាមួយសុំបញ្ចូលឯកសារភស្តុតាងដែលរកមិនបាននៅពេលបិទការបទបង្ហាញសំណុំឯកសាររបស់ខ្លួន *"ការចោទសួរសំខាន់ដែលត្រូវពិចារណា [...] គឺសួរថា បើបានប្រឹងប្រែងអស់ចិត្តហើយ តើភាគីដើមបណ្តឹងបានកំណត់ និងដាក់បញ្ចូលភស្តុតាងទាំងនោះ ក្នុងក្របខណ្ឌនៃបទបង្ហាញតាមមធ្យោបាយរបស់ខ្លួនហើយឬនៅ"*[4] ។

៧. ជាការពិតណាស់ដែលថា អង្គជំនុំជម្រះសាលាសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងប្រទេសរវ៉ាន់ដា បានអះអាងជាច្រើនលើកច្រើនសាថាឯកសារភស្តុតាងអាចត្រូវចាត់ទុកថាមិនអាចរកបាន នៅក្នុងពេលបើកសវនាការ ប្រសិនបើការប្រឹងប្រែងអស់លទ្ធភាពមិនអាចឲ្យភាគីដើមបណ្តឹងរកបាននូវភស្តុតាងទាំងនោះទេ។[5]

៨. បើទោះបីជាដើមបណ្តឹងរដ្ឋប្បវេណី យល់ស្របថាឯកសារភស្តុតាងដែលបានលើកឡើងនោះអាចរកបានជាសាធារណៈ មុននឹងដាក់បញ្ចូលក្នុងបញ្ជីនៃដើមបណ្តឹងយ៉ាងណាក្តី តែមេធាវីនៅតែគាំទ្រគំនិតដែលថា *"បន្ទាប់ពីការស្រាវជ្រាវយ៉ាងស៊ីជម្រៅ ទើបដើមបណ្តឹងរដ្ឋប្បវេណីអាចរកបានឯកសារក្នុងពេលថ្មីៗ និងកំណត់យកឯកសារនោះ"*[6]។

---

[3] ដូចខាងលើ

[4] សេចក្តីសម្រេចទាក់ទិននឹងឯកសារថ្មីៗ និងបញ្ហាពាក់ព័ន្ធដទៃទៀត ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១២ ឯកសារ **E190** ។ អង្គជំនុំជម្រះសាលាដំបូងផ្អែកជាពិសេសទៅលើយុត្តិសាស្ត្រដូចតទៅ ៖ *រឿងក្តីនៃរដ្ឋអាជ្ញា តទល់នឹង* Delalić និងបក្ខពួក សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី រឿងក្តី IT-96-21-A ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌទី ២៨៣

[5] សេចក្តីសម្រេចទាក់ទិននឹងឯកសារថ្មីៗ និងបញ្ហាពាក់ព័ន្ធដទៃទៀត ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១២ ឯកសារ **E190** កថាខណ្ឌទី២៣។

[6] ការស្នើសុំដាក់ភស្តុតាងបន្ថែមជូនអង្គជំនុំជម្រះសាលាដំបូង ដោយអនុលោមតាមវិធាន៨៧.៤ នៃវិធានផ្ទៃក្នុង ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ ឯកសារ **E289** កថាខណ្ឌទី១០។

៩. ក្រុមមេធាវីការពារក្តី លោក ខៀវ សំផន សូមអះអាងថាការផ្តល់ហេតុផលរបស់សហមេធាវីនៃដើមបណ្តឹងរដ្ឋប្បវេណីមិនបានគ្រប់គ្រាន់ ពីព្រោះលោកមេធាវីមិនបានពន្យល់ឱ្យបានគ្រប់គ្រាន់ថាហេតុអ្វីបានជាមិនអាចទទួលបានឯកសារនេះមុនបើកសវនាការ បើទោះបីជាបានខិតខំប្រឹងប្រែងអស់លទ្ធភាពទៅហើយក្តី។[7]

១០. តាមពិតទៅ ការអះអាងរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី គឺទទួលស្គាល់ដោយខ្លួនឯងទៅវិញទេថា ការស្រាវជ្រាវរបស់សហមេធាវីមិនបាន "ស៊ីជម្រៅ" ឡើយ ក្នុងការស្វែងរកភស្តុតាងទាំងនេះ។ គ្រាន់តែធ្វើការស្វែងរកតែប៉ុន្មានសប្តាហ៍មុនពេលបិទការបង្ហាញភស្តុតាង ក៏នរណាម្នាក់អាចរកបាន តាមប្រព័ន្ធអ៊ីនធើណែត នូវរលកវិទ្យុមួយក្នុងចំណោមវិទ្យុដែលគេស្តាប់ច្រើនជាងគេបង្អស់នៅប្រទេសបារាំងមួយនេះដែរ។[8]

១១. វាជាការច្បាស់ណាស់ដែលថា ស្ថានភាពបែបនេះ មិនអាចបំពេញតាមបទបញ្ញត្តិស្របច្បាប់ឡើយ ហើយការផ្តល់ហេតុផលដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី គឺមិនគ្រប់គ្រាន់ចំពោះកាតព្វកិច្ចក្នុងការខិតខំប្រឹងប្រែងសម្រាប់ភាគីផ្សេងៗនៅក្នុងរឿងក្តី។

១២. ម្យ៉ាងវិញទៀត ដូចជាអង្គជំនុំជម្រះសាលាដំបូង បានរំឭករួចមកហើយ រយៈពេលដែលពន្យារ ចន្លោះពេលនៃការចាត់វិធានការជាក់ស្តែងក្នុងការទទួលបានឯកសារ ឬភាពយឺតយ៉ាវគ្មានហេតុផលរវាងខណៈពេលដែលគេរកបានឯកសារ និងពេលដាក់ពាក្យសុំទទួលយកឯកសារជាភស្តុតាង អាចបញ្ជាក់បានថា ភាគីដើមបណ្តឹងមិនបានខំប្រឹងប្រែងឱ្យអស់លទ្ធភាពនោះឡើយ។[9]

១៣. ចំពោះចំណុចនេះ ក្រុមមេធាវីការពារក្តី លោក ខៀវ សំផន កត់សម្គាល់ថា សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី មិនទាំងបានបង្ហាញពីកាលបរិច្ឆេទ នៅពេលបានដឹងថាឯកសារមានទៀតផង ហើយមិនទាំងបានរៀបរាប់ថាតើកាលៈទេសៈអ្វីដែលនាំឱ្យមេធាវីរកបានឯកសារយឺតយ៉ាវបែបនេះសោះឡើយ។ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក៏មិននៅអែអង់ដែរ ចំពោះថិរវេលាកំណត់រវាងពេលដែលរកឃើញឯកសារនោះ និងការសុំដាក់បញ្ចូលឯកសារដើម្បីបានការយល់ព្រមយកវាធ្វើជាភស្តុតាង។ ក៏ប៉ុន្តែ បើគេអានយុត្តិសាស្ត្រនៃអង្គជំនុំជម្រះសាលា

---

[7] ដូចខាងលើ កថាខណ្ឌទី១០។

[8] ដូចខាងលើ។

[9] សេចក្តីសម្រេចទាក់ទិននឹងឯកសារថ្មីៗ និងបញ្ហាពាក់ព័ន្ធដទៃទៀត ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១២ ឯកសារ **E190** កថាខណ្ឌទី២៣។

ដំបូងនៃ អ.វ.ត.ក ពត៌មានទាំងនោះពិតជាចាំបាច់ខ្លាំងណាស់ សម្រាប់វាយតម្លៃទៅលើការខំប្រឹងប្រែងយកចិត្តទុកដាក់ឲ្យអស់លទ្ធភាពរបស់ភាគី។[10]

១៤. ជាសេចក្តីសន្និដ្ឋាន ភាពយឺតយ៉ាវនៃការរកឃើញឯកសារ និងភាពមិនរឹងមាំនៃអំណះអំណាងដែលលើកឡើងដើម្បីបញ្ជាក់ហេតុផលនៃការបញ្ចូលឯកសារទៅក្នុងការពិភាក្សាដេញដោល ប៉ុន្មានសប្តាហ៍មុនពេលបិទសវនាការសម្រាប់ការបង្ហាញភស្តុតាង សបញ្ជាក់ឲ្យឃើញពីកំហុសនៃសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ដែលមិនបានប្រឹងប្រែងឲ្យបានអស់លទ្ធភាព ទៅតាមអត្ថន័យនៃបទបញ្ញានីតិវិធី និងយុត្តិសាស្ត្រដែលអាចអនុវត្តបាន នៅក្នុងករណីពិសេសនេះ។ ខណៈដែលអង្គជំនុំជម្រះសាលាដំបូង ក្នុងពេលថ្មីៗនេះ សុខចិត្តឲ្យបញ្ចូលឯកសារថ្មីៗក្នុងការពិភាក្សាដេញដោល ដូចជាខ្សែវីដេអូរបស់អតីតមហាក្សត្រ នរោត្តម សីហនុ ក៏ព្រោះតែវីដេអូនេះជាភស្តុតាងដោះបន្ទុកមួយ ដូច្នេះវាផ្តល់នូវធាតុថ្មីៗ មានប្រយោជន៍សម្រាប់ស្វែងរកការពិត។[11] ក៏ប៉ុន្តែ ផ្ទុយពីការអះអាងរបស់ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី បទសម្ភាសនេះមិនបានផ្តល់នូវធាតុថ្មីៗដែលមានប្រយោជន៍ស្វែងរកការពិតសោះឡើយ។

## II. ភាពមិនសមស្រួបរវាងការស្នើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីជាមួយនឹង "អត្ថប្រយោជន៍ដើម្បីយុត្តិធម៌"

១៥. សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី យល់ឃើញ "*ថាគួរតែយល់ព្រមទទួលយកឯកសារថ្មីនេះ ដោយសារតែវាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹង ឯកសារភស្តុតាងដទៃទៀត ដែលបានដាក់បញ្ចូលក្នុងសំណុំឯកសារនិយាយពីលោកខៀវសំផន ពាក់ព័ន្ធនឹងតួនាទីរបស់គាត់នៅក្នុងរបប ប៉ុល ពត។ ឯកសារនេះមានប្រយោជន៍ និងមានភាពចាំបាច់សម្រាប់ស្វែងរកការពិត និងចុងបញ្ចប់វាឆ្លើយតបទៅនឹងអត្ថប្រយោជន៍ដើម្បីស្វែងរកយុត្តិធម៌*"[12] ។

១៦. ជាការពិតណាស់ អង្គជំនុំជម្រះសាលាដំបូងបានយល់ព្រមថាអង្គជំនុំជម្រះអាចដាក់

---

[10] ដូចខាងលើ។

[11] ចម្លើយរបស់អង្គជំនុំជម្រះទៅនឹងសំណើតាមវិធាន ៨៧.៤ នៃវិធានផ្ទៃក្នុងរបស់សហព្រះរាជអាជ្ញា ជនជាប់ចោទ នួន ជា និង ខៀវ សំផន (ឯកសារ E236/4/1, E265, E271, E276 et E276/1) កថាខណ្ឌទី៦។

[12] ការស្នើសុំដាក់ភស្តុតាងបន្ថែមជូនអង្គជំនុំជម្រះសាលាដំបូង ដោយអនុលោមតាមវិធាន៨៧.៤ នៃវិធានផ្ទៃក្នុង ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ ឯកសារ **E289** កថាខណ្ឌទី១០។

ចម្លើយទៅនឹងការស្នើសុំដាក់ភស្តុតាងបន្ថែមលើកទី១នៃសហមេធាវីនាំមុខនៃដើមបណ្តឹងរដ្ឋប្បវេណី ដោយអនុលោមតាមវិធាន៨៧.៤ នៃវិធានផ្ទៃក្នុង

បញ្ចូលក្នុងសំណុំឯកសារនូវភស្តុតាងដែលបង្ហាញជូនយឺតយ៉ាវ ខណៈដែលឯកសារទាំងនោះមិនមានអ្វីថ្មី បើយើងគិតដល់ន័យចង្អៀតរបស់ពាក្យនេះ ប្រសិនបើគេមើលឃើញថាភស្តុតាងដែលពាក់ព័ន្ធមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងភស្តុតាងដទៃទៀតដែលបានដាក់បញ្ចូលពេលមុនៗនោះ។[13] ក្នុងករណីនេះ អង្គជំនុំជម្រះបានវាយតម្លៃថាអាចទទួលយកភស្តុតាងទាំងនេះ ប្រសិនបើអត្ថប្រយោជន៍ដើម្បីយុត្តិធម៌តម្រូវពិនិត្យមើលក្នុងពេលជាមួយគ្នានូវឯកសារបែបនេះ ជាមួយនឹងឯកសារដែលបានដាក់បញ្ចូលនៅពេលមុនៗទៅក្នុងសំណុំឯកសារ។

១៧. អង្គជំនុំជម្រះសាលាដំបូងនានានៃតុលាការពិសេស ក៏បានយល់ព្រមទទួលជាលក្ខណៈពិសេសនូវការស្នើសុំកែប្រែបញ្ជីដើមនៃភស្តុតាងនៅក្នុងពេលបង្ហាញឯកសារនៃភាគី។ ករណីនេះធ្លាប់កើតឡើង នៅពេលដែលអង្គជំនុំជម្រះទាំងនោះជឿជាក់ថាមានការលើកឡើងនូវហេតុផលគ្រប់គ្រាន់ ហើយភស្តុតាងថ្មីៗក៏មានភាពសមស្រប និងមានសារៈសំខាន់ខ្លាំង ល្មមអាចជាហេតុផលនៃការបន្ថែមដោយយឺតយ៉ាវបាន។[14]

១៨. នៅក្នុងករណីពិសេសនេះ ក្រុមមេធាវីការពារក្តី លោក ខៀវ សំផន សូមបញ្ជាក់ថា ហេតុផលដែលបានលើកឡើងមិនមានលក្ខណៈគ្រប់គ្រាន់ឡើយ។ ពីព្រោះថា វាជាការសំខាន់ណាស់ក្នុងការកត់សម្គាល់ថា ការបកស្រាយសម្រង់នៃបទសម្ភាស ដែលធ្វើឡើងដោយសហមេធាវីនាំមុខសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការសរសេរការស្នើសុំរបស់ខ្លួន គឺជាការបកស្រាយខ្លឹមសារមិនត្រឹមត្រូវ និងលម្អៀង។ ជាឧទាហរណ៍ សហមេធាវីបានអះអាងថា បទសម្ភាសនេះអាចឲ្យគេបង្ហាញថា "[លោក ខៀវ សំផន] បានដឹងយ៉ាងច្បាស់ពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត" ក៏ប៉ុន្តែ លោក ខៀវ សំផន បាននិយាយផ្ទុយពីនោះសោះ។ ព្រោះថា នៅក្នុងកិច្ចសម្ភាសនោះ លោក ខៀវ សំផន បានអះអាងថាលោកមិនបានដឹងអ្វីទាល់តែសោះ ចំពោះរឿងដែលកើតឡើងនៅកន្លែងកើតហេតុ៖ *"ខ្ញុំសូមបញ្ជាក់ប្រាប់ថា ដរាបណាយើងមិនចេញពីបរិវេណនោះទេ គេមិនអាចដឹងរឿងអ្វីឡើយ។ ពួកយុទ្ធជនមិនបាននិយាយទេ"*[15]។ ការបក

---

[13] សេចក្តីសម្រេចទាក់ទិននឹងឯកសារថ្មីៗ និងបញ្ហាពាក់ព័ន្ធដទៃទៀត ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១២ ឯកសារ **E190** កថាខណ្ឌទី២១។ សូមអានផងដែរនូវចម្លើយរបស់អង្គជំនុំជម្រះទៅនឹងសំណើតាមវិធាន ៨៧.៤ នៃវិធានផ្ទៃក្នុងរបស់សហព្រះរាជអាជ្ញា ជនជាប់ចោទ នួន ជា និង ខៀវ សំផន (ឯកសារ E236/4/1, E265, E271, E276 et E276/1) ថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៣ ឯកសារ **E276/2** កថាខណ្ឌទី៣។

[14] ដូចខាងលើ។

[15] ប្រតិចារឹកឡើងវិញនៃបទសម្ភាសជាមួយ លោក ខៀវ សំផន នៅក្នុងវិទ្យុបារាំង France Culture ខែសីហា ឆ្នាំ ចម្លើយទៅនឹងការស្នើសុំដាក់ភស្តុតាងបន្ថែមលើកទី១នៃសហមេធាវីនាំមុខនៃដើមបណ្តឹងរដ្ឋប្បវេណី ដោយអនុលោមតាមវិធាន៨៧.៤ នៃវិធានផ្ទៃក្នុង

ស្រាយមិនត្រឹមត្រូវរបស់សហមេធាវី គឺជាមូលដ្ឋានបង្អែកនៃអំណះអំណាង ដែលថាបទសម្ភាសនេះ មានភាពចាំបាច់សម្រាប់ស្វែងរកការពិត។ ទាំងនេះមិនសមស្របទៅតាមលក្ខណៈវិនិច្ឆ័យ និងហេតុផលដែលទទួលស្គាល់ដោយសេចក្តីសម្រេចចិត្តនៃតុលាការអន្តរជាតិឡើយ។

១៩. ពីព្រោះថា សេចក្តីសម្រេចចិត្តទាំងនោះ គិតគូរម៉ត់ចត់ទៅដល់ភាពចាំបាច់ក្នុងការការពារឲ្យបានសមស្របនូវសិទ្ធិរបស់ជនជាប់ចោទ។[16] ទាំងយុត្តិសាស្ត្រនៃអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក ក៏ដូចជាយុត្តិសាស្ត្រដែលរៀបរៀងដោយតុលាការពិសេសដទៃទៀត សុទ្ធតែគូសបញ្ជាក់ពីភាពចាំបាច់នៃការថ្លឹងថ្លែងឲ្យបានស្មើគ្នានូវសិទ្ធនៃមេធាវីការពារក្តីក្នុងការទទួលបាននូវព័ត៌មានលម្អិតជាមុននូវភស្តុតាងដាក់បន្ទុក និងកាតព្វកិច្ចនៃព្រះរាជអាជ្ញាក្នុងការរកភស្តុតាងពិរុទ្ធភាពនៃជនជាប់ចោទ។

២០. ជាឧទាហរណ៍ នៅពេលស្រង់សម្តីពីក្នុងយុត្តិសាស្ត្រនៃតុលាការព្រហ្មទណ្ឌអន្តរជាតិដើម្បីអតីតប្រទេសយូហ្គោស្លាវី អង្គជំនុំជម្រះសាលាដំបូង នៅក្នុងសេចក្តីសម្រេចពាក់ព័ន្ធនឹងឯកសារថ្មីៗ បានគូសបញ្ជាក់ថា "*អង្គជំនុំជម្រះសាលាដំបូងបានយល់ព្រមទទួលការស្នើសុំនេះ* ***<u>ក្នុងករណីពិសេស</u>*** *ក្នុងការកែប្រែបញ្ជីដំបូងនៃភស្តុតាង [...]* ***<u>ដោយថ្លឹងថ្លែងចំណុចនេះយ៉ាងយកចិត្តទុកដាក់ ជាមួយនឹងភាពចាំបាច់ក្នុងការការពារសិទ្ធិជនជាប់ចោទឲ្យបានសមស្រប</u>***"[17]
។

២១. ក៏ប៉ុន្តែ ក្នុងករណីពិសេសនេះ ការស្នើសុំដែលធ្វើឡើងដោយ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី គឺពិតជាយឺតយ៉ាវជ្រុលពេក ហើយបង្ហាញពីកំហុសនៃសហមេធាវីនាំមុខក្នុង

---

២00៧ ទំព័រទី៣

[16] រឿងក្តីរបស់រដ្ឋអាជ្ញា តទល់នឹង *Haradinaj* និងបក្ខពួក *Trial Chamber's clarification on whether the Prosecutor must request leave to amend its Rule 65 ter exhibit list* រឿងក្តីលេខ No. IT-04-84-T ថ្ងៃទី២៥ ឧសភា ឆ្នាំ២00៧ កថាខណ្ឌទី៤។

[17] សេចក្តីសម្រេចទាក់ទិននឹងឯកសារថ្មីៗ និងបញ្ហាពាក់ព័ន្ធដទៃទៀត ថ្ងៃទី៣0 ខែមេសា ឆ្នាំ២0១២ ឯកសារ **E190** កថាខណ្ឌទី២៣ កំណត់ជើងទំព័រទី៣0។ អង្គជំនុំជម្រះសាលាដំបូងបានផ្អែកជាពិសេសទៅលើសេចក្តីសម្រេចរឿងក្តីរបស់រដ្ឋអាជ្ញា តទល់នឹង *Popović* និងបក្ខពួក *Decision on Appeals against decision admitting material related to Borovčanin's questionning* រឿងក្តីលេខ No. IT-05-88-AR73.1 ថ្ងៃទី១៤ ធ្នូ ឆ្នាំ២00៧ កថាខណ្ឌទី៣៧។

ចម្លើយទៅនឹងការស្នើសុំដាក់ភស្តុតាងបន្ថែមលើកទី១នៃសហមេធាវីនាំមុខនៃដើមបណ្តឹងរដ្ឋប្បវេណី ដោយអនុលោមតាមវិធាន៨៧.៤ នៃវិធានផ្ទៃក្នុង

ករណីយកិច្ចរបស់ខ្លួនដែលត្រូវតែខំប្រឹងប្រែង។ ដូច្នេះ សហមេធាវីការពារក្តី លោក ខៀវ សំផន ចាត់ទុកការទទួលយកឯកសារភស្តុតាងបែបនេះ នៅក្នុងពេលតែប៉ុន្មានសប្តាហ៍មុនពេលបិទសវនាការពាក់ព័ន្ធនឹងការបង្ហាញភស្តុតាង ថាជាការរំលោភទៅនឹងសិទ្ធិមូលដ្ឋានរបស់ជនជាប់ចោទដែលមានសិទ្ធិទទួលបានព័ត៌មានគ្រប់គ្រាន់ជាមុននូវឯកសារភស្តុតាងដែលអាចដាក់បញ្ចូលក្នុងសំណុំឯកសារ ដើម្បីរៀបចំការការពារក្តីប្រកបដោយប្រសិទ្ធភាព។

២២. ដោយហេតុថា អង្គជំនុំជម្រះមានករណីយកិច្ចទទួលស្គាល់ថា "ក្នុងករណីពិសេស" នូវការស្នើសុំកែប្រែបញ្ជីដំបូងនៃភស្តុតាង ដោយ"*ដោយថ្លឹងថ្លែងចំណុចនេះយ៉ាងយកចិត្តទុកដាក់ជាមួយនឹងភាពចាំបាច់ក្នុងការការពារសិទ្ធិជនជាប់ចោទឱ្យបានសមស្រប*" ដូច្នេះទទួលយកការស្នើសុំនោះ មិនខុសអ្វីពីរំលោភលើសិទ្ធិរបស់ លោក ខៀវ សំផន ក្នុងការទទួលបានការកាត់សេចក្តីប្រកបដោយសមធម៌ ដូចមានកំណត់នៅក្នុងបទដ្ឋាននីតិវិធីអន្តរជាតិនោះឡើយ។

២៣. ដូច្នេះ ដោយសារតែវាប៉ះពាល់ទៅលើ សិទ្ធិមូលដ្ឋានរបស់ លោក ខៀវ សំផន ដោយសារតែការទទួលយកឯកសារនេះ ការដាក់បញ្ចូលឯកសារនេះទៅក្នុងការពិភាក្សាដេញដោលមិនអាចចាត់ទុកតាមផ្លូវច្បាប់ដោយអង្គជំនុំជម្រះ មិនអនុលោមទៅតាម "អត្ថប្រយោជន៍ដើម្បីយុត្តិធម៌" សោះឡើយ។

២៤. **អាស្រ័យហេតុនេះ** ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងមេត្តា៖

- **ធ្វើការសន្និដ្ឋាន**ថាការស្នើសុំដាក់បញ្ចូលឯកសារថ្មីនេះទៅក្នុងសំណុំឯកសារ ពិតជាមានភាពយឺតយ៉ាវជ្រុលពេក និងបង្ហាញពីកំហុសរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីដែលមិនបានប្រឹងប្រែងឱ្យអស់លទ្ធភាព។

- **បញ្ជាក់** ថាការស្នើសុំដាក់បញ្ចូលឯកសារថ្មីនេះទៅក្នុងសំណុំឯកសារ ផ្ទុយទៅនឹងសញ្ញាណនៃ "អត្ថប្រយោជន៍ដើម្បីយុត្តិធម៌" ដូចមានកំណត់នៅក្នុងយុត្តិសាស្ត្រតុលាការពិសេស និងយុត្តិសាស្ត្រនៃអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក និង

- ***ប្រកាស*** ថាមិនអាចទទួលយកបាននូវឯកសារនេះ ដោយអនុលោមទៅតាមវិធាន ៨៧.៤ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ឡើយ។

# រក្សាសិទ្ធិកែប្រែគ្រប់យ៉ាង
# និងដើម្បីយុត្តិធម៌

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន<br>មេធាវី Anta GUISSÉ<br>មេធាវី Artur VERCKEN<br>មេធាវី Jacques VERGÈS | ភ្នំពេញ<br>ប៉ារីស<br>ភ្នំពេញ<br>ប៉ារីស | |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |